# បច្ចេកទេសសម្ភាសន៍

## ក. ការត្រៀមរៀបចំ

- **ពតិមានអំពីដៃគូសម្ភាសន៏របស់អ្នកនិងអង្គការរបស់គាត់**

  មុនពេលអ្នកចាប់ផ្ដើមជាមួយនឹងការសម្ភាសន៏ ចូរព្យាយាមរកពតិមានឱ្យបានច្រើនតាមតែអាចធ្វើបានអំពីដៃគូសម្ភាសន៏របស់អ្នក និងអង្គការរបស់គាត់ដែលគាត់កំពុងធ្វើការឱ្យ ។

- **ត្រៀមសំណួរទាំងឡាយ** ដែលអ្នកពិតជាចង់យកមកឱ្យឆ្លើយ ។

- **បញ្ជីសំណួរ**

  ត្រៀមបញ្ជីពិនិត្យ (Check list) សំនួរដែលអ្នកអាចសង្កត់សួរក្នុងពេលធ្វើសម្ភាសន៏ ។

- **ការត្រៀមផ្នែកបច្ចេកទេស**

  ត្រៀមសម្ភារៈទាំងអស់របស់អ្នកឱ្យបានរួចជាស្រេចៈ

  - យកក្រដាសឱ្យគ្រប់ ( សៀវភៅកំណត់ហេតុ)
  - ពិនិត្យមើលម៉ាញ៉េថតសម្លេង និងថ្ម ( យកកាសែតបន្ថែមនៅពេលការសម្ភាសន៏ប្រើរយៈពេលវែង)
  - កុំភ្លេចខ្មៅដៃ
  - យកនាមបណ្ណ័ទៅជាមួយអ្នក

## ខ. សេចក្ដីផ្ដើម

រាល់ការសម្ភាសន៏ចាប់ផ្ដើមដោយមិនមានសំនួរទេ ប៉ុន្តែចាប់ផ្ដើមជាមួយនឹងពតិមានមួយចំនួនដែលអ្នកផ្ដល់ដល់ដៃគូសម្ភាសន៏របស់អ្នក :

- **ឈ្មោះ**: " ខ្ញុំឈ្មោះ ........."
- **ប្រវត្តិការងារ**: " ខ្ញុំធ្វើការងារឱ្យ ..." ឬ "ខ្ញុំជាមន្ត្រីកម្មវិធីនៃ ..."
- **គោលបំណងនៃការសម្ភាសន៏**: " ខ្ញុំចង់ដឹងបន្ថែមទៀតអំពី ....."
  " ខ្ញុំធ្វើការស្ទាបស្ទង់អំពី ...... "
  " ខ្ញុំត្រូវការស្វែងយល់អំពី .... "
- **ពេលវេលា** : " ការសម្ភាសន៏របស់ខ្ញុំ នឹងប្រើពេល ១០ នាទី "
  " ខ្ញុំសូមយកពេលរបស់លោកចំនួន ១៥ នាទី "

## គ. **សំនួរ**

ជានិច្ចជាកាល សូមរក្សាសំនួររបស់អ្នកឱ្យខ្លីហើយច្បាស់លាស់ ។ កុំនិយាយច្រើនជាងដៃគូសម្ភាសរបស់អ្នក ។ ធ្វើដូចនេះដំណើរការប្រសើរបំផុតនៅពេលដែលអ្នកចាប់ផ្ដើមដោយសំណួរមួយក្នុងចំណោមសំនួរ "W" ។

**អ្នកណា ?** (**W**ho?)
**អ្វី?** (**W**hat?)
**ពេលណា?** (**W**hen?)
**ហេតុអ្វី?** (**W**hy?)
**ទីណា? (ទៅទីណា? មកពីណា?)** (**W**here? **W**here ... to? **W**here ... from?)
**ដូចម្ដេច?** (How?)

## ឃ. **ការសួរសំនួរក្នុងពេលសម្ភាសន៍:**

### ១. រៀនគិតថា " **ខ្ញុំចង់បានចម្លើយមួយ** "

ដំបូងអ្នកត្រូវតែរកគំនិតច្បាស់លាស់នូវអ្វីដែល អ្នក **ចង់បាន**ដោយផ្ទាល់ខ្លួនពីការសម្ភាសន៍: ដូច្នេះចូរសួរខ្លួនឯង:

- <u>ខ្ញុំចង់បានអ្វី?</u> ខ្ញុំចង់បានចម្លើយ !
- <u>ខ្ញុំមានគោលបំណងអ្វី?</u> ខ្ញុំចង់បានមនុស្សដែលមកធ្វើសម្ភាសន៍ដើម្បីផ្ដល់**ពតិមាន**ឱ្យខ្ញុំ ។
- <u>ហេតុអ្វីបានជាខ្ញុំចង់បានពតិមាន?</u>

  ... ពីព្រោះខ្ញុំ **ត្រូវការ**សរសេររបាយការណ៍
  ... ពីព្រោះ ខ្ញុំ**ត្រូវការ**ពិនិត្យលើករណីសិទ្ធិមនុស្ស
  ... ពីព្រោះខ្ញុំ **ត្រូវការ**ត្រៀមរៀបចំយុទ្ធសាស្ត្របញ្ចុះបញ្ចូល ។ល។

- <u>តើខ្ញុំមានសិទ្ធិសួរសំនួរដែរឬទេ</u> ?

  បាទ/ចាស វាជា**សិទ្ធិរបស់ខ្ញុំ**ក្នុងការសួរ ។ សេរីភាពនៃកាសំដែងមតិរបស់ខ្ញុំក៏រួមបញ្ចូលផងដែរនូវលទ្ធភាពទទួលបានពតិមានដោយសេរី ។ ខ្ញុំតែងតែអាចសាកល្បងជានិច្ច ។

ប្រសិនបើអ្នក មិនច្បាស់លាស់អំពីគោលបំណងផ្ទាល់ខ្លួន និងសេចក្ដីត្រូវការរបស់អ្នកទេ អ្នកនឹងងាយបាត់ស្មារតីលើសំនួររបស់អ្នក ដោយសារមនុស្សដែលឆ្លើយនឹងសំណួររបស់អ្នក ។

លុះណាតែអ្នកច្បាស់លាស់អំពីគោលបំណងនិងសេចក្ដីត្រូវការរបស់អ្នក ទើបអ្នកនឹងមានអារម្មណ៍មោះមុតដោយខ្លួនឯងគ្រប់គ្រាន់ដើម្បីប្រកាន់ភ្ជាប់នូវសំណួររបស់អ្នក ហើយអ្នកនឹងមិនយល់ស្របឆាប់រហ័សជាមួយនឹងចម្លើយដែលមិនគ្រប់គ្រាន់ឡើយ ។

**ពង្រឹងអាត្មាជាមុនសិន** មុនពេលអ្នកទៅសម្ភាសន៍អ្នកណាម្នាក់ !

**ទាមទារឱ្យអ្នកណាម្នាក់ផ្តល់ចម្លើយ គឺជាជំហានដំបូងនៃការសម្ភាសន៍ ។** ត្រូវតែធ្វើអ្វីមួយដោយមានការត្រួតពិនិត្យ និងការត្រួតត្រាមើល ។ សំនួរទាមទារឱ្យអ្នកណាម្នាក់បញ្ចេញនូវពត៌មាននិងគំនិតរបស់គាត់ ឬបង្ហាញនូវការសមហេតុសមផលខ្លួនគេ ។ ដូច្នេះត្រូវតែធ្វើយ៉ាងច្បាស់លាស់ជាមួយការអនុវត្តន៍អំណាច ។ មនុស្សដែលសួរសំនួរអនុវត្តអំណាច ។ គាត់បញ្ចេញនូវបំណងប្រាថ្នាហួត់ចត់ ការទាមទារថា អ្នកណាផ្សេងទៀតបញ្ចេញអ្វីមួយឱ្យគាត់ឃើញ ។ ដូច្នេះមនុស្សដែលត្រូវគេសួរសំនួរ តែងតែមិនចូលចិត្តឱ្យគេសួរទេ។

ដូច្នេះ ចូរដឹងអំពីស្ថានភាពនេះ!

ប៉ុន្តែ កុំស្ទាក់ស្ទើរក្នុងការសួរសំនួរពិព្រោះតែអ្នកចង់សម្តែងគួរសម ឬ ពីព្រោះតែអ្នកមិនចង់រុញច្រានអ្នកណាម្នាក់ ។

បើមិនដូច្នោះទេ ពេលវេលាសម្ភាសន៍របស់អ្នកត្រូវអស់ ហើយអ្នកត្រូវត្រឡប់ទៅវិញដោយគ្មាន លទ្ធផល (**ពត៌មាន**) ដែលអ្នកចង់បានឡើយ ។

## ២. រឿនគិតៈ “ **ខ្ញុំប្រកាន់ភ្ជាប់ក្នុងរង្វង់សំនួររបស់ខ្ញុំ** ”
## “ **ខ្ញុំទទូចចង់បានចម្លើយ**”

**ទាមទារអ្នកណាម្នាក់ឱ្យត្រឡប់មករកសំនួររបស់អ្នកជាញឹកញាប់ គឺជាការចាំបាច់** ក្នុងអំឡុងពេលសម្ភាសន៍ ។ ការទាមទាររបៀបនេះ ទៅឆ្ងាយជាងសំនួរដំបូង ។ វាបង្ហាញថា អ្នកសម្ភាសន៍មិនយល់ស្រប តាមយ៉ាងពេញលេញជាមួយចម្លើយដំបូងទេ ក៏ប៉ុន្តែចង់បានការពន្យល់បន្ថែមទៀត ។ សំនួររបៀបនេះ លើកឡើងនូវការឆ្លល់បន្តិចបន្តួចអំពីភាពគ្រប់គ្រាន់នៃចម្លើយដំបូង ។ មនុស្សជាច្រើន នឹងមិនចូលចិត្តឱ្យគេសួរសំនួរថែមទៀតទេ ។ គេគិតថាចម្លើយមួយគឺល្អមគ្រប់គ្រាន់ហើយ ។ អ្នកធ្វើសម្ភាសន៍មិនសមនឹងទទួលចម្លើយថែមទៀតទេ ។

ចូរដឹងអំពីស្ថានភាពនេះ!

ប៉ុន្តែ កុំទប់មិនឱ្យមានការសួរសំនួរទីពីរ និងទទូចចង់បានចម្លើយដែលអ្នកចង់បាន ។

**ត្រឡប់មកសំនួររបស់អ្នកវិញ!**

ឧទាហរណ៍:

អ្នកកំពុងសួរអ្នកណាម្នាក់ថា តើគំរោងកម្មវិធីរបស់គាត់ជោគជយ័ឬទេ ។ គាត់ឆ្លើយថា គំរោងកម្មវិធីនឹងដំណើរការបន្ត ។ នេះមិនមែនជាចម្លើយទេ ប្រសិនបើគំរោងកម្មវិធីពិតជាជោគជយ័ ឬមិនជោគជយ័ ប៉ុន្តែគ្រាន់តែជៀសវាងចម្លើយច្បាស់លាស់ (អ្នកណាក៏អាចបន្តជាមួយគំរោងកម្មវិធីមិនជោគជយ័បានដែរ ពីព្រោះគាត់មិនចង់សារភាពអំពីការខ្វះជោគជ័យទេ!) ។

**ដូច្នេះ ចូរចាំក្នុងចិត្តនូវអង្គហេតុដែលអ្នកនឹងតែងតែមានតែនៅក្នុងរយៈពេលមានកំរិត សំរាប់កិច្ចសម្ភាសន៍ ដែលអ្នកត្រូវដឹកនាំមនុស្សឱ្យត្រឡប់មកសំណួររបស់អ្នក ។**

អញ្ចឹងតើអ្វីអ្នកនឹងធ្វើ?

អ្នកអាចនិយាយថា : "លោកមិនបានឆ្លើយសំនួររបស់ខ្ញុំទេ ! ខ្ញុំសូមនិយាយម្តងទៀតថា ខ្ញុំត្រូវការពត៌មានអំពីបញ្ហានេះ ។ កុំព្យាយាមជៀសវាងសំនួរម្តងទៀត ! "

តាមពិតទៅ ធ្វើដូចនេះវាឆ្គាំឆ្គងនិងមិនគួរសមទេ ។

ដូច្នេះ ជាការប្រសើរគួរតែនិយាយថា :

"អ្នកបានបរិយាយនូវចំណុចគួរឱ្យចាប់អារម្មណ៍ ។ ប៉ុន្តែខ្ញុំមានរយៈពេលមានកំរិត ហើយខ្ញុំក៏ចាប់អារម្មណ៍ដែរអំពី ... (រំលឹកដល់សំណួរដំបូងរបស់ខ្ញុំ)" ។

ឬ

"ខ្ញុំសុំទោស ប៉ុន្តែតើអ្នកអាចផ្តល់ឱ្យខ្ញុំឱ្យបានលំអិតជាងនេះបានទេអំពី ... (រំលឹកដល់សំនួរដំបូង)?"

**ការនិយាយកាត់ដៃគូសម្ភាសន៍របស់អ្នក:**

សូមមានអារម្មណ៍សេរីក្នុង**ការនិយាយកាត់**ដៃគូសម្ភាសន៍របស់អ្នក ប្រសិនបើគាត់និយាយច្រើនពេក! ប្រសិនបើអ្នកមិននិយាយកាត់ទេ អ្នកនឹងបាត់បង់ពេលវេលាខ្លីដ៏មានតម្លៃរបស់អ្នក សំរាប់អ្វីដែលអ្នកមិនចង់ដឹង!

ឧទាហរណ៍:

"អត់ទោសដែលខ្ញុំសុំកាត់អ្នកបន្តិច ប៉ុន្តែខ្ញុំត្រូវការសួរនូវសំនួរបន្ទាប់ទៀត ។"

## ៣. រៀនគិតថា **"ហេតុអ្វី"**

ប្រសិនបើអ្នកសួរអ្វីមួយ អ្នកនឹងតែងតែទទួលចម្លើយ ។ ប៉ុន្តែចម្លើយ នឹងមិនតែងតែគ្រប់គ្រាន់ទេ!

ដូច្នេះ កុំយល់ស្របនិងពេញចិត្តពេញថ្លើមជាមួយនឹងអង្គហេតុពិតដែលអ្នកគ្រាន់តែទទួលបានចម្លើយ ។ ប៉ុន្តែគិតជាលក្ខណៈទិទៀនៈ តើចម្លើយនេះពន្យល់គ្រប់គ្រាន់ឬទេ? មូលហេតុអ្វី ដែលដៃគូសម្ភាសន៍របស់ខ្ញុំអាចមានសំរាប់ចម្លើយនេះ? តើខ្ញុំយល់ចម្លើយឬទេ? តើចម្លើយនេះនាំឱ្យមានសំនួរបន្ថែមទៀតឬទេ ?

បញ្ជីខាងក្រោមនេះអាចអនុវត្តចំពោះចម្លើយណាមួយក៏បាន ហើយនឹងផ្តល់ឱ្យអ្នកនូវឧបករណ៍ខ្លះៗ ដើម្បីគិតទិទៀនអំពីចម្លើយនេះ ហើយមិនដឹងថាវាទាក់ទាញអ្នកឱ្យតាម ឬមិនទាក់ទាញ:

### ១.១. តើចម្លើយផ្អែកលើមូលដ្ឋានអ្វី?

**តើចម្លើយផ្អែកលើ...**

- **...បទពិសោធន៍?**

វាមិនគ្រប់គ្រាន់ទេដែលមនុស្សដែលឆ្លើយ គ្រាន់តែមានឋានន្តរស័ក្តិខ្ពស់ ឬមានអំណាច ។

ដូច្នេះ ចូរសួរដូចជា : "តើអ្នកធ្លាប់សាកល្បងនូវអ្វីដែលអ្នកស្នើឥឡូវនេះដែរឬទេ ?"

"តើបញ្ហានេះធ្លាប់បានពិនិត្យ សាកល្បងជាក់ស្តែងឬទេ ?"

"តើអ្នកមានបទពិសោធន៍អ្វីខ្លះពាក់ពន្ធ័នឹងរឿងនេះ សូមផ្តល់ឱ្យខ្ញុំនូវឧទាហរណ៍ខ្លះៗនៃបទពិសោធន៍ដែលអ្នកបានធ្វើ ?"

"តើអ្នកដោះស្រាយបញ្ហានេះអស់រយៈប៉ុន្មានហើយ?

- **...អង្គហេតុ ?**

ចម្លើយអាចផ្អែកតែទៅលើការចោទប្រកាន់ធម្មតា ដោយគ្មានមូលដ្ឋានជាក់ស្តែងណាមួយទេ ។
ដូច្នេះ ចូរសួរដូចជា: " សូមផ្តល់ឱ្យខ្ញុំនូវអង្គហេតុខ្លះៗ - ចំនួន ? "
" តើរឿងនេះផ្អែកលើការស្មង់មតិ ឬ តាមការសិក្សា ? ការសិក្សាណាមួយ ?
" តើអ្នកទទួលភាគរយនេះបានយ៉ាងដូចម្តេច ? "
" តើចម្លើយរបស់អ្នកមានមូលដ្ឋានលើរបាយការណ៍ ឬភស្តុតាងអ្វី? "

- **...លើច្បាប់ ឬវិធានដែលទទួលយកបានជារួម ?**

វាមិនគ្រប់គ្រាន់ទេ ប្រសិនបើមន្ត្រីរដ្ឋាភិបាលគ្រាន់តែនិយាយថា: "នេះគឺខុសច្បាប់" ឬប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលមួយគ្រាន់តែនិយាយថា: " នេះគឺរំលោភសិទ្ធិមនុស្ស" ។
ដូច្នេះ ចូរសួរដូចជា: " តើលោកចង់មានន័យប្រាកដលើច្បាប់អ្វី? លោកអាចលើកយកមាត្រាមកបានឬទេ?"
"តើលោកឃើញថា រំលោភសិទ្ធិមនុស្សត្រង់ចំណុចណាប្រាកដ? សូមផ្តល់ឱ្យខ្ញុំឱ្យបានលំអិតបន្ថែមខ្លះដែលខ្ញុំអាចរកឃើញបាន ?"

**១.២. តើដៃគូសម្ភាសន៍របស់អ្នកបានសម្តែងឥរិយាបទអ្វីខ្លះតាមរយៈចម្លើយរបស់គាត់ ?**

**តើចម្លើយបង្ហាញថា មនុស្សដែលសម្ភាសន៍ ...**

- **...មានទស្សនៈសំរាប់អនាគតឬទេ?**

ដើម្បីពិនិត្យទស្សនៈរបស់ចម្លើយដែលអ្នកអាចសួរបន្ថែមនូវសំនួរជាសម្មិតិកម្ម( ការស្មាន)ខ្លះពាក់ពន្ធ័នឹងអនាគត : "តើលោកគិតថាក្នុងរយៈពេលពីរឆ្នាំទៀតនេះ វានឹងមានសភាពយ៉ាងដូចម្តេច?"
"តើអ្នកគិតថានឹងមានស្ថានភាពអាក្រក់បំផុតអ្វីខ្លះក្នុងរយៈពេលពីរឆ្នាំទៀត/មានស្ថានភាពល្អបំផុតអ្វីខ្លះ?"
"តើលោកមានចក្ខុវិស័យអ្វីខ្លះ?"

- **...ចង់រួមចំណែកយ៉ាងសកម្មដល់សង្គមឬទេ?**

ដើម្បីស្វែងរកបញ្ហានេះដោយផ្ទាល់ ចូរសួរអំពីការលើកទឹកចិត្ត និងគោលបំណងរបស់ដៃគូសម្ភាសន៍:
"តើអ្វីខ្លះនាំឱ្យលោកធ្វើកិច្ចការដ៏ពិបាកនេះ?"
"តើលោកមានចក្ខុវិស័យអ្វីខ្លះ?"
"ហេតុអ្វីបានជាលោកគិតថា ធ្វើដូចនេះ នឹងពង្រឹងស្ថានភាពរបស់សង្គម?"
"តើលោកគិតថា ធ្វើដូចនោះមានផលចំណេញអ្វីខ្លះ?"

- **...អត់ធ្មត់នឹងទស្សនៈផ្សេងៗទៀតឬទេ?**

ដើម្បីរកឱ្យឃើញថាតើដៃគូសម្ភាសន៍ជាមនុស្សមានទស្សនៈបើកចំហឬទេ សូមសួរគាត់ទស្សនៈច្រើនបែបៈ
" សូមយើងនឹកស្រម៉ៃថា លោកនៅខាងភាគីម្ខាងទៀត ។ តើលោកធ្វើយ៉ាងណា?"
"តើលោកមានគំនិតថាអ្វីជាការប្រឆាំងនឹងលោកឬទេ.ឬការនិយាយទិទៀនចំពោះរឿងនេះ ?"
"ហេតុអ្វីបានជាលោកគិតថារឿងនេះក៏ជាការទាក់ទាញសំរាប់ក្រុមជំទាស់ ឬក្រុមភាគតិច ?"

### ១.៣. តើដៃគូសម្ភាសន៍ព្យាយាមជៀសវាងចម្លើយច្បាស់លាស់ឬទេ?

- **តើគាត់ផ្លាស់ប្តូរប្រធានបទនៃសំណួររបស់អ្នកឬទេ?**

ជានិច្ចជាកាលចូរពិនិត្យមើលក្រែងចម្លើយនោះនៅតែមានអ្វីមួយដែលត្រូវធ្វើជាមួយនឹងសំនួររបស់អ្នក ។ ក្នុងករណីដៃគូសម្ភាសន៍គ្រាន់តែប្តូរទៅលើចំណាប់អារម្មណ៍មួយទៀតនោះ ចូរអ្នកសួរដូចនេះ:

"ប្រហែលជាសំនួររបស់ខ្ញុំមិនសូវច្បាស់លាស់ ។ ដូច្នេះខ្ញុំសូមរៀបចំសំនួរដែលខ្ញុំសួរឱ្យកាន់តែច្បាស់ ។ ជាប្រាកដទៅខ្ញុំចង់ដឹងអំពី..."

- **តើចម្លើយរបស់គាត់មិនច្បាស់ឬមានលក្ខណៈស្រពិចស្រពិល (ដោយគ្មានលំអិតដែលអាចពិនិត្យបាន ឬទេ)?**

ជានិច្ចជាកាល ចូរពិនិត្យលើថាតើចម្លើយនោះពិតជាផ្តល់អង្គហេតុ និងសាច់រឿងលំអិតដែលអាចបញ្ជាក់ភស្តុតាងឬទេ ។ ប្រសិនបើចម្លើយឆ្លើយថា មិនមានអ្នកអាចសួរថា :

"តើលោកអាចផ្តល់ឱ្យខ្ញុំនូវសាច់រឿងលំអិតលើបញ្ហានោះបានឬទេ?"

"តើលោកអាចនិយាយឈ្មោះមនុស្សមួយចំនួនដែលខ្ញុំអាចសួរអំពីបញ្ហានេះបានឬទេដើម្បីជាការស្រាវជ្រាវបន្ថែមទៀត?"

"តើលោកមានប្រភពនៃពតិមានរបស់លោកឬទេ ?"

### ១.៤. តើអ្វីគុណភាពនៃអំនះអំនាងរបស់ដៃគូសម្ភាសន៍?

គុណភាពនៃអំនះអំនាងណាមួយនៅក្នុងការពិភាក្សា អាស្រយ័លើធាតុ បី យ៉ាង:

- **ចំណុចចាប់ផ្តើម** គឺថា មូលដ្ឋានសំអាងនានា
- **ជំហានសមហេតុសមផល** និងសេចក្តីសន្និដ្ឋាននានាដែលចេញពីចំណុចចាប់ផ្តើមនោះទៅរកលទ្ធផលចុងក្រោយ (ដំណោះស្រាយ ចម្លើយ)
- **លទ្ធផលនោះ**

រាល់គំនិតគឺផ្អែកលើមូលដ្ឋានសំអាងទាំងឡាយ ។ ចាប់ផ្តើមពីចំណុចនេះ ប្រើជំហានគិតមួយចំនួនដើម្បីយកមកសន្និដ្ឋាន ។ ជំហានទាំងនេះ ត្រូវសមហេតុសមផល ។ នោះមានន័យថា វាទាក់ទាញឱ្យតាម និងងាយស្រួលអនុវត្តតាម ។ ប្រសិនបើ អ្នកណាម្នាក់ប្រើជំហានដូចគ្នាដដែល គាត់អាចមានសេចក្តីសន្និដ្ឋានដូចគ្នាដែរ ។ ហើយនៅទីបំផុត លទ្ធផលឬ ដំណោះស្រាយនោះ អាចអនុវត្តបានឬមិនបាន អាចនៅក្នុងច្បាប់ ឬមិននៅអាចមិនមានភាពជាក់ស្តែងទាំងស្រុង ឬអាចបើកចំហដល់ដំណោះស្រាយស្ថិតស្ថេរសំរាប់អនាគត ។ ដូច្នេះ អ្នកគួរពិនិត្យចម្លើយ និងអំនះអំនាងទាំងឡាយរបស់ដៃគូសម្ភាសន៍របស់អ្នក ជានិច្ចជាកាលតាមរយៈការពិនិត្យអង្គធាតុទាំង បី នេះ:

- **តើមូលដ្ឋានសំអាង ទាក់ទាញឱ្យតាមឬទេ?**

ឧទាហរណ៍ថា ដៃគូសម្ភាសន៍របស់អ្នកចាប់ផ្តើមដោយការនិយាយថា: "ដូចដែលយើងទាំងអស់គ្នាដឹងហើយថា មនុស្សគ្រប់រូបត្រូវការការអនុញ្ញាតដើម្បីធ្វើបាតុកម្មជាសាធារណៈ" ឬ"លោកនឹងយល់ស្របថា រដ្ឋធម្មនុញ្ញ ពិតជាទាត់ចោលការរួមគ្នារបស់គណបក្សនានាក្រោយការបោះឆ្នោត" ឬឧទាហរណ៍ថា "បញ្ហាគ្រឿងញៀនគឺបណ្តាលមកពីការរត់ពន្ធមកពីប្រទេសថៃ" ។

បញ្ហានេះអាចត្រូវ ។ ប៉ុន្តែបញ្ហានេះអាចខុសរួចស្រេចទៅហើយ ។ ប្រសិនបើដៃគូសម្ភាសន៍របស់អ្នកឆ្លាតវៃ គាត់នឹងអាចបង្កើតបានជាមូលដ្ឋានសំអាងរួចជាស្រេច ដូចជាបញ្ហាអង្គហេតុ ដែលអ្នកមានអារម្មណ៍ថា ជំរុញឱ្យធ្វើតាមដោយងាយ ។

ដូច្នេះជានិច្ចជាកាល សូមពិនិត្យដូចនេះហើយសួរគាត់:

"តាមខ្ញុំយល់ពីមូលដ្ឋានសំអាង របស់លោកគឺ..."

"ហេតុអ្វីបានជាលោកគិតថា រឿងនេះត្រូវ? លោកអាចផ្តល់ឱ្យខ្ញុំនូវការពន្យល់បន្ថែមទៀតបានទេលើមូលដ្ឋានសំអាងរបស់អ្នក ?"

- **តើវិធីដើម្បីធ្វើសេចក្តីសន្និដ្ឋាននោះសមហេតុសមផលដែរឬទេ?**

ដៃគូសម្ភាសន៍របស់អ្នកអាចនិយាយថា: "យើងមិនត្រូវការការចូលរួមរបស់ប្រជាពលរដ្ឋនៅថ្នាក់ខេត្តតាមរយៈការបោះឆ្នោតជ្រើសរើសអភិបាលខេត្តទេ ពីព្រោះ យើងមានការចូលរួមរបស់ប្រជាពលរដ្ឋរួចទៅហើយ នៅថ្នាក់ជាតិ និងនៅថ្នាក់ឃុំ" ។ នៅពេលដែលអ្នកមើលយ៉ាងជិតដិតទៅបញ្ហានោះ នេះមិនមែនជាគំនិតសមហេតុសមផលទេ ពីព្រោះវាប្រាកដជាមិនពន្យល់ច្បាស់លាស់អំពីកង្វះខាតនៃការចូលរួមនៅថ្នាក់ខេត្ត និង ហេតុអ្វីត្រូវមានអញ្ញត្រកម្ម (ការលើកលែង) លើគោលការណ៍ស្វយ័ដឹកនាំដែលអាចអនុវត្តបាននៅគ្រប់កំរិតថ្នាក់ទាំងអស់នៃរដ្ឋាភិបាល ។

ដូច្នេះអ្នកអាចសួរថា: "តើលោកគិតថាមានភាពខុសគ្នារវាងថ្នាក់ខេត្ត និងថ្នាក់ឃុំឬទេ ដែលនឹងបង្ហាញនូវការសមហេតុសមផលលើអញ្ញត្រកម្មនៃស្វ័យដឹកនាំ ដូចនេះ?"

- **តើលទ្ធផលអាចទទួលយកបានជាក់ស្តែង អាចអនុវត្តបានដែរឬទេនៅក្នុងជីវភាពជាក់ស្តែង ?**

អ្នកនយោបាយឆ្លើយមកអ្នកថា: "ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្ម យើងមិនគួរដាក់ទោស មន្ត្រីនគរបាលដែលមើលដោយអកម្ម (ដោយមិនធ្វើអ្វី) ចំពោះការសម្លាប់មនុស្សក្នុងហ្វូងមនុស្ស" អ្នកអាចសួរថា: "តើអ្នកគិតថាបញ្ហានេះ ស្របទៅនឹងរដ្ឋធម្មនុញ្ញដែរឬទេ?"

# បច្ចេកទេសក្នុងការសម្ភាសន៍

## ការរៀបចំត្រៀម

**ការរៀបចំត្រៀម**
- ទទួលពត៌មានអំពីអ្នកដែលត្រូវសម្ភាសន៍
- រៀបចំតារាងសំនួរ
- ឧបករណ៏បច្ចេកទេស

**ការណែនាំខ្លួនឯង**
- ឈ្មោះ
- សារីតា
- គោលបំណង
- រយ:ពេលសម្ភាសន៍

**សំណួរនាំមុខដោយអក្សរ "W"**
- អ្នកណា? (who?)
- អ្វី? (what?)
- ពេលណា? (when?)
- ហេតុអ្វី? (why?)
- នៅឯណា? (where?)
- យ៉ាងដូចម្តេច? (how?)

→

## ការរៀបចំផ្នែកខាងចិត្តសាស្ត្រ

ការពិចារណា

ក. "ខ្ញុំចង់បានចំលើយ"
(តើខ្ញុំចង់បានអ្វី/ តើខ្ញុំត្រូវការអ្វី?)

ខ. "ខ្ញុំប្រកាន់ខ្ជាប់នូវសំនួររបស់ខ្ញុំ"
"ខ្ញុំទទូចចង់បានចំលើយដែលខ្ញុំត្រូវការ"

-ត្រឡប់ទៅរកសំនួររបស់អ្នកវិញ ដោយ
- បង្អាក់ អ្នកដែលត្រូវសម្ភាសន៍ ។

→

## គិតឱ្យបានស៊ីជំរៅ: សួរថា "ហេតុអ្វី?"

| | | |
|---|---|---|
| តើចំលើយមានមូលដ្ឋានលើ<br>• បទពិសោធន៏?<br>• អង្គហេតុ?<br>• ច្បាប់,វិធាន ?<br><br>តើអ្នកដែលត្រូវគេសម្ភាសន៏បង្ហាញពី<br>• ទស្សវិស័យទៅអនាគត?<br>• ការរួមវិភាគទានសំរាប់សង្គម?<br>• ការអធ្យាស្រ័យសំរាប់ទស្សនៈផ្សេងៗ? | តើអ្នកដែលត្រូវគេសម្ភាសន៏មិនព្រមផ្តល់នូវចំលើយឱ្យច្បាស់លាស់ ទេឬ?<br><br>តើគាត់/នាង ផ្លាស់ប្តូរប្រធានបទនៃសំនួរ ?<br><br>តើចំលើយមានលក្ខណ:មិនច្បាស់លាស់ ? | តើអំណះអំណាងគួរឱ្យជឿដែរឬទេ ?<br><br>• តើចំនុចចាប់ផ្តើម (ការនិយាយដំបូង, ការសន្និដ្ឋាន) គួរឱ្យជឿទេ ?<br>• តើរបៀបនៃការគិត មានលក្ខណ:សមហេតុផលដែរឬទេ ?<br>• តើលទ្ធផលដែលមានលក្ខណ:ស្របច្បាប់ គេចូលចិត្តប្រើនៅក្នុងជីវិតពិតអាចត្រូវបានគេជួយឧបត្ថម្ភដែរឬទេ? |